# បុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក

## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១ ព្រះសហគមន៍សន្តីម៉ារីញញឹម (តាកែវ)

## "ព្រះវិញ្ញាណដ៏វិសុទ្ធជម្រុញយើងឱ្យយើងទៅប្រកាសដំណឹងល្អ"

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ដែលយើងគោរពបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទន្ទឹងរង់ចាំ។ យើងបានរៀបចំផ្កា ដែលមានរាងជាបេះដូងក្រហម ហើយពាក់កណ្ដាលមានពណ៌សដែរ។ ផ្កានេះ ណែនាំឱ្យយើងនឹកឃើញដល់សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលយាងចូលនៅក្នុងដួងចិត្តរបស់យើងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ ពីព្រះឈើឆ្កាង យើងមានក្រណាត់ក្រហម និងក្រណាត់ពណ៌មាស ណែនាំឱ្យយើងនឹកឃើញដល់របៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង របៀបដែលព្រះជាម្ចាស់បានណែនាំឱ្យយើងចូលនៅក្នុងជីវិតរបស់ព្រះអង្គតែម្ដងតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ ពិតមែនជាពេលវេលាដើម្បីទូលអង្វរឱ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។

ឱ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើយើង មកសណ្ឋិតលើយើងរៀងៗខ្លួន ដូចកាលពីដើមព្រះវិញ្ញាណដ៏វិសុទ្ធបានសណ្ឋិតលើក្រុមគ្រីស្តទូត។
ឱ្យព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើសង្គមរបស់យើងបច្ចុប្បន្ននេះ ដូចពីដើមព្រះវិញ្ញាណដ៏វិសុទ្ធបានសណ្ឋិតលើទីក្រុងយេរូសាឡឹម។
ឱ្យព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើព្រះសហគមន៍យើងខ្ញុំ ដូចកាលពីដើមព្រះវិញ្ញាណដ៏វិសុទ្ធបានសណ្ឋិតលើក្រុមគ្រីស្តទូត ដែលបានជួបជុំគ្នាជាមួយព្រះនាងម៉ារី ជាមួយគ្រីស្តបរិស័ទខ្លះៗដែលកំពុងអធិដ្ឋាន។

បងប្អូនជាទីស្រឡាញ់ នៅក្នុងអត្ថបទទី២ យើងបានស្ដាប់ផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺ "**សេចក្ដីស្រឡាញ់ ចិត្តអត់ធ្មត់ បរិសុទ្ធ ជំនឿ ចិត្តលើកលែងទោស**"។ ប៉ុន្តែ ព្រះវិញ្ញាណដ៏វិសុទ្ធបានណែនាំឱ្យយើងទទួលព្រះអំណោយទានដ៏ពិសេសទាំង៧។ ថ្ងៃនេះ ជារៀងរាល់ឆ្នាំសម្រាប់ខ្ញុំដែលជាអភិបាលរបស់ព្រះសហគមន៍កាតូលិក គឺជាពេលវេលាដើម្បីធ្វើអគ្គសញ្ញាលាបថ្ងាស ដល់បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរយៈពេលមួយឆ្នាំកន្លងមក។ ថ្ងៃនេះយើងធ្វើមិនបាន

ប៉ុន្តែថ្ងៃនេះយើងភ្ជាប់ចិត្តរួមជាមួយប្អូនៗ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក ដោយទូលអង្វរដល់ព្រះវិញ្ញាណដ៏វិសុទ្ធសូមយាងមក។ប៉ុន្តែមិនមែនតែសណ្ឋិតលើគេ គឺសណ្ឋិតលើយើងដែរ។

*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងមានប្រាជ្ញាឈ្លាសវៃ*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងស្គាល់សេចក្ដីពិត*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងមានយោបល់ល្អ*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងចេះទទួលខុសនិងត្រូវ*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងមានចិត្តអង់អាចក្លាហាន*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងគោរពព្រះអម្ចាស់យេស៊ូជាព្រះអម្ចាស់របស់យើង*
*ព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានណែនាំឱ្យយើងធ្វើតាមព្រះហឫទ័យរបស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិត។*

នេះជាព្រះអំណោយទានទាំង៧ដែលយើងបានទទួល ជាព្រះអំណោយទានទាំង៧ដែលបានណែនាំឱ្យយើងអាចគិតពិចារណា សម្រាប់យើងជាគ្រីស្តបរិស័ទក្នុងពេលបច្ចុប្បន្ននេះ នៅក្នុងសង្គមដែលកំពុងរស់នៅក្នុងការទុក្ខលំបាក។ **តើព្រះវិញ្ញាណដ៏វិសុទ្ធ អាចណែនាំយើងដើម្បីឱ្យយើងទៅជាមនុស្សថ្មីដូចម្ដេច?** ណែនាំយើងឱ្យយើងមានគំនិតថ្មីៗ ណែនាំយើងឱ្យយើងចេះទទួលខុសត្រូវយ៉ាងច្បាស់លាស់ ណែនាំយើងឱ្យយើងមានសេចក្ដីក្លាហានអង់អាច ណែនាំយើងឱ្យយើងយកព្រះជាម្ចាស់ជាទីពឹងតែមួយព្រះអង្គគត់ ដើម្បីធ្វើដំណើរនៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គមបច្ចុប្បន្ននេះ តាមព្រះវិញ្ញាណដ៏វិសុទ្ធដែលបើកផ្លូវដ៏អស្ចារ្យសម្រាប់ជីវិតរបស់យើងពិតមែន។

បងប្អូនជាទីស្រឡាញ់ ប្រសិនបើយើងពិចារណាអំពីស្ថានភាពសព្វថ្ងៃ យើងបានឃើញចាប់ពីថ្ងៃនេះប្រហែលព្រះវិញ្ញាណដ៏វិសុទ្ធដែលបានគង់នៅដែរ រាជធានីភ្នំពេញដូចជាបានបើកទ្វារសារជាថ្មី ផ្សារសាធារណៈក៏បានបើកទ្វារសារជាថ្មី ការបិទបម្រាមគោចរក៏ត្រូវបានបញ្ចប់។ យើងអាចនិយាយបានថា រាជធានីភ្នំពេញនៅសល់តែតំបន់ពណ៌លឿង និងនៅសល់តំបន់ពណ៌ទឹកក្រូចចាស់តែ៥កន្លែង នេះជាអ្វីដែលយើងបានឃើញ។ ប៉ុន្តែ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឱ្យយើងមើលឃើញស្ថានភាពនានាដែរ ហើយកូវីដ-១៩ដែលបានថយនៅក្នុងរាជធានីភ្នំពេញ ដូចជាបានសម្រេចចិត្តធ្វើដំណើរទៅតាមខេត្ត។ ដោយសារ ប្រសិនបើយើងមើលនៅតាមខេត្តនីមួយៗ ជារៀងរាល់ថ្ងៃមានអ្នកឆ្លងជំងឺកូវីដ-១៩ ពី៥០ដល់១០០នាក់ ឬលើសហ្នឹងក្នុងករណីថ្មីៗ។ ដូច្នេះ នៅពេលនេះយើងមិនអាចនិយាយថា យើងនៅក្នុងពេលវេលាដែលពោរពេញដោយសុវត្ថិភាពបានទេ។ ប្រសិនបើ យើងមើលហើយពិចារណាសាលាក៏នៅតែបន្តបិទទ្វារដដែល យើងបានឃើញសកម្មភាពជួបជុំគ្នាជាលក្ខណៈគ្រួសារយ៉ាងធំ ឬអាពាហ៍ពិពាហ៍ ឬពិធីបុណ្យនានា ក៏នៅតែមិនទាន់ដំណើរការបានដដែល។ យើងឃើញសកម្មភាពសាសនានានា ក៏នៅតែមិនអាចធ្វើដដែល ហើយថ្ងៃនេះដែលខ្ញុំបានថ្វាយអភិបូជា ពីព្រះសហគមន៍សន្តីម៉ារីញញឹម ចំការទៀង ក្នុងខេត្ត

តាកែវ យើងក៏ដឹងថាមានប៉ុន្មានព្រះសហគមន៍ក៏នៅតែមិនទាន់មានអភិបូជាដដែល ទោះបីថ្ងៃនេះជាថ្ងៃអាទិត្យផង និងជាបុណ្យឱឡារិកដ៏កំពូលរបស់ព្រះសហគមន៍ផង។

ប្រសិនបើ យើងស្តាប់ស្ថានភាពរបស់ពិភពលោក យើងបានដឹងថាមានជិត ៣លាននាក់ ដែលបានទទួលមរណៈភាពដោយសារជំងឺកូវីដ-១៩។ ប៉ុន្តែ យើងអាចគុណចំនួននេះជា២ឬជា៣ សម្រាប់អ្នកដែលបានស្លាប់ពីឆ្នាំ២០១៩ ឆ្នាំ២០២០ និងឆ្នាំ២០២១ ដោយសាររងឥទ្ធិពលដ៏អាក្រក់នៃជំងឺកូវីដ-១៩។ ដោយសារ មនុស្សដែលខ្វះម្ហូបអាហារក៏មានច្រើនថែមទៀត មនុស្សដែលមិនអាចមានលទ្ធភាពទៅមន្ទីរពេទ្យ ដើម្បីទទួលការព្យាបាលក៏មានច្រើនថែមទៀត។ ដូច្នេះ ស្ថានភាពរបស់ពិភពលោកក៏នៅតែមិនទាន់ស្រួលសោះ។ ហេតុនេះហើយ ប្រសិនបើយើងមើលទាំងឥទ្ធិពលផ្ទាល់ដែលយើងទទួលពីជំងឺកូវីដ-១៩ ទាំងឥទ្ធិពលដែលយើងទទួលផ្សេងៗពីជំងឺកូវីដ-១៩ ក៏បានណែនាំឱ្យយើងបន្តរស់នៅក្នុងបរិយាកាស ដែលធ្វើឱ្យយើងភ័យខ្លាចជានិច្ច។ សង្គមរបស់យើងបានធ្លាក់ចុះ សេដ្ឋកិច្ចរបស់យើងក៏បានធ្លាក់ចុះ និងជាពិសេសសេដ្ឋកិច្ចគ្រួសារមួយចំនួនយ៉ាងធំក៏បានធ្លាក់ចុះ សកម្មភាពនៅក្នុងព្រះសហគមន៍របស់យើងក៏បានធ្លាក់ចុះ។ ប្រសិនបើ យើងពិចារណាពីប៉ុន្មានខែកន្លងមក សកម្មភាពរបស់យើងដូចជាជិតអស់ហើយ លើកលែងតែសញ្ញានៃធម៌មេត្តាករុណាដែលយើងបានយកចិត្តទុកដាក់ធ្វើនៅតាមកន្លែងនីមួយៗ។

ដូច្នេះ បងប្អូនជាទីស្រឡាញ់នៅពេលដែលយើងបានស្តាប់ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីឱ្យយើងមានប្រាជ្ញាស្លៀងវៃ ព្រះវិញ្ញាណដ៏វិសុទ្ធយើងមកដើម្បីឱ្យយើងមានគំនិតល្អ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីឱ្យយើងចេះទទួលខុសនិងត្រូវ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកដើម្បីឱ្យយើងមានសេចក្តីក្លាហាន។ សប្តាហ៍មុន ខ្ញុំបានអញ្ជើញមណ្ឌលសកម្មភាពនីមួយៗក្នុងភូមិភាគភ្នំពេញឱ្យយើងប្រមូលបញ្ជីឈ្មោះបេក្ខជនអ្នកដែលទទួលការអប់រំជំនឿ។ នៅក្នុងនេះ មានអ្នកដែលកំពុងត្រៀមទទួលជំហានទី១ និងអ្នកដែលកំពុងត្រៀមជំហានទី២ ក្មេងៗដែលកំពុងត្រៀមទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត និងយុវជនក៏ដូចជាមនុស្សពេញវ័យដែលកំពុងត្រៀមទទួលអគ្គសញ្ញាលាបថ្ងាស ក៏ដូចជាក្រុមពន្លកថ្មី។ សរុបមក ខ្ញុំបានទទួលចម្លើយតែ២មណ្ឌលសកម្មភាព ដូច្នេះខ្ញុំសង្ឃឹមថា យើងនឹងយកចិត្តទុកដាក់ថែមទៀតតាមមណ្ឌលសកម្មភាពនីមួយៗ ដើម្បីរៀបចំជាបន្ទាន់។ ហេតុនេះហើយ យើងអាចរៀបចំកម្មវិធីអប់រំជំនឿពីចម្ងាយ (តាម Online) ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធបានណែនាំឱ្យយើងមានគំនិតល្អ ណែនាំឱ្យយើងមានសេចក្តីក្លាហាន ណែនាំឱ្យយើងទទួលខុសត្រូវយ៉ាងខ្ពស់ មិនមែនទទួលខុសត្រូវល្មមៗទេ។

ដូច្នេះ នេះជាពេលវេលាដើម្បីឱ្យសប្តាហ៍ក្រោយ ខ្ញុំសុំឱ្យមណ្ឌលសកម្មភាពនីមួយៗ ហើយខ្ញុំក៏សង្ឃឹមថាលោកឪពុកកំពុងស្តាប់ខ្ញុំ ឱ្យយើងមានកម្មវិធីអប់រំជំនឿចាប់ពីម៉ោង ៧.៣០នាទីព្រឹករហូតដល់ម៉ោង៨.៣០នាទីព្រឹក។ ម៉ោងជិត ៩.00ព្រឹកយើងអាចចូលអភិបូជាពីចម្ងាយ (តាម Online ក្នុងហ្វេសបុកភេច https://www.facebook.com/LiveCatholicChannel)។ ប្រសិនបើ យើង

ពិចារណាអភិបូជាពីចម្ងាយ (តាម Online) យើងមានប្រហែលតែ១០០នាក់ជាង ដែលបានចូលប្រចាំរាល់សប្តាហ៍។ ប៉ុន្តែ ប្រសិនបើយើងមិនបានចូលថ្វាយអភិបូជាជាពីចម្ងាយ (តាម Online) ជាមួយភូមិភាគ មានន័យថាជាមួយខ្ញុំ **តើយើងចូលអភិបូជារបៀបណាសព្វថ្ងៃ?** អត់មាន ដោយសារអភិបូជាពីចម្ងាយ (តាម Online) មានតែមួយ គឺអភិបូជាដែលលោកអភិបាលថ្វាយថ្ងៃអាទិត្យ ហើយតាមកន្លែងផ្សេងៗសព្វថ្ងៃយើងប្រហែលជាអត់មានអភិបូជាទេ ឬអាចមានកន្លែងខ្លះដែលមានថ្វាយអភិបូជាជាមួយគ្រីស្តបរិស័ទតែ៤ឬ៥នាក់តែប៉ុណ្ណឹង។ ដូច្នេះ យើងត្រូវតែលើកទឹកចិត្តឱ្យគ្នាទៅវិញទៅមក ដើម្បីឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ពិតមែនយើងមិនចែកតាមផ្លូវដូចក្រុមគ្រីស្តទូតពីដើម ដែលយើងបានស្តាប់ថ្ងៃនេះ។ ប៉ុន្តែ យើងអាចមានយោបល់ល្អថែមទៀត យើងអាចមានមធ្យោបាយល្អថែមទៀត ដើម្បីឱ្យអភិបូជានិងការអធិដ្ឋានបានទៅដល់កន្លែងនីមួយៗ។ ថ្ងៃនេះ ជាពេលវេលាមួយដែរដើម្បីនឹកឃើញ ជាពិសេសដល់កុមារព្រោះថា យើងជិតដល់ថ្ងៃទី១ ខែមិថុនាដែលជាទិវាគោរពសិទ្ធិកុមារអន្តរជាតិ ដល់យុវជនយុវនារី ដល់ជំទង់។

ពីម្សិលមិញ ខ្ញុំបានប្រជុំជាមួយមេក្រុមកាយរិទ្ធនៅក្នុងតំបន់ភ្នំពេញ តំបន់តាខ្មៅ តំបន់បាសាក់ និងតំបន់មេគង្គ។ យើងក៏បានស្តាប់សក្ខីភាពរបស់មេកាយរិទ្ធិ ដែលពីប៉ុន្មានខែយើងមិនអាចជួបជុំគ្នាមែន (ដោយសារតែយើងមិនមានឱកាសដើម្បីជួបជុំគ្នា) ប៉ុន្តែយើងអត់មានសកម្មភាពផ្សេងៗដែរ សកម្មភាពពីចម្ងាយ (តាម Online) ក៏អត់ ការចុះសួរសុខទុក្ខក៏អត់ក៏ពិបាកមែនទែន។ ដូច្នេះ ជាពេលវេលាមួយដើម្បីឱ្យនៅក្នុងសប្តាហ៍នេះ ខ្ញុំផ្ញើឯកសារទៅតាមលោកឪពុកនីមួយៗនៅក្នុងមណ្ឌលសកម្មភាពទាំង៩ ដើម្បីបញ្ចូលឈ្មោះយ៉ាងច្បាស់លាស់ ប្រធានក្រុមកាយរិទ្ធិ ប្រធានក្រុមយុវជន និងប្រធានក្រុមជំទង់ ដើម្បីឱ្យយើងគិតថែមទៀត។ ដោយសារ ជាមួយការិយាល័យយុវជន ជំទង់ និងកុមារ យើងមានសកម្មភាពច្រើន ប៉ុន្តែសកម្មភាពរបស់យើងជាមួយតំណាង។ ដូចពីម្សិលមិញ ខ្ញុំមានតំណាងត្រឹមតែ១៨ទៅ២០នាក់តែប៉ុណ្ណឹង ប៉ុន្តែយើងដឹងថាតាមព្រះសហគមន៍នីមួយៗ យើងមានមេកាយរិទ្ធ១០នាក់ ២០នាក់ ៣០នាក់។ ម្សិលមិញ ជួបជាមួយយើងតែតំណាង ដូច្នេះយើងធ្វើដូចម្តេចដើម្បីឱ្យតំណាងផ្សាយតដល់សមាជិកក្នុងក្រុមរបស់ខ្លួន ដែលមាន១០នាក់ ដែលមាន២០នាក់ តាមមូលដ្ឋាន តាមព្រះសហគមន៍នីមួយៗ និងតាមព្រះវិហារនីមួយៗ។

ជួនកាល យើងនិយាយថាអប់រំជំនឿពិបាកណាស់ យាយចាស់ៗដែលអត់ចេះប្រើទូរស័ព្ទទំនើប ឬមិនចេះប្រើប្រព័ន្ធអ៊ីនធឺណេត។ ប៉ុន្តែ ពួកគាត់ក៏មានកូនចៅនៅក្បែរដែលអាចជួយបង្ហាញគាត់បានដែរ។ យុវជនយុវនារី ដែលយើងកំពុងតែនិយាយនៅក្នុងរាជធានីភ្នំពេញជាពិសេស នៅក្នុងទីក្រុងតាខ្មៅជាពិសេស នៅទីក្រុងនានាដែលយើងមាន នៅតាមភូមិនានា។ សព្វថ្ងៃ ដែលកំពុងរៀនពីចម្ងាយ (តាម Online) មានខ្លះគេរៀនពីចម្ងាយ (តាម Online) មួយថ្ងៃ៦ម៉ោង មានខ្លះគេរៀនតាមពីចម្ងាយ (តាម Online) ថ្ងៃសៅរ៍ថ្ងៃអាទិត្យ៨ម៉ោងក្នុងមួយថ្ងៃ។ ដូច្នេះ ខ្ញុំជឿថាយើងជាព្រះសហគមន៍កាតូលិក យើងមានមធ្យោបាយដើម្បីទៅដល់យុវជនយុវនារីរបស់យើង យ៉ាងតិចនៅក្នុងមួយសប្តាហ៍មួយម៉ោងឬពីរម៉ោង ដើម្បីអប់រំ ដើម្បីសួរសុខទុក្ខគ្នាទៅវិញទៅមក។

ខ្ញុំក៏សូមអរគុណ និងសូមអរព្រះគុណព្រះជាម្ចាស់ ដោយសារខ្ញុំបានឃើញផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ។ ពីប៉ុន្មានដង ខ្ញុំបានចូលពីចម្ងាយ (តាម Online) ក្នុងកម្មវិធី ZOOM ឬហ្វេសប៊ុក ជាមួយយុវជន គឺជាពេលវេលាមួយដែលយុវជនម្នាក់ៗចែកអំពីទុក្ខលំបាក អំពីអំណរសប្បាយ អំពីសេចក្តីសង្ឃឹម និងអំពីសំណូមពររបស់គាត់ នេះជាភាពកក់ក្តៅសម្រាប់គាត់។ ដូច្នេះ យើងត្រូវការបន្តទៅដល់កន្លែងនីមួយៗដ៏តូច កុំឱ្យយើងគិតតែកម្រិតភូមិភាគភ្នំពេញតែប៉ុណ្ណឹង។ បងប្អូនជាទីស្រឡាញ់ យើងត្រូវតែមានគំនិតថ្មី យើងត្រូវតែទទួលខុសត្រូវយ៉ាងខ្ពស់ យើងត្រូវតែមានសេចក្តីក្លាហានជានិច្ច។

ដូច្នេះ នៅថ្ងៃទី១ ខែមិថុនា កម្មវិធីសិទ្ធិកុមារអន្តរជាតិយើងលើកដល់ថ្ងៃអាទិត្យ (២សប្តាហ៍ទៀត)។ នៅពេលនោះ យើងទៅសួរសុខទុក្ខកូនក្មេងតាមផ្ទះ ដែលយើងនឹងចែកជូនសម្ភារៈការសិក្សាជាពិសេស ឱ្យកូនក្មេងសប្បាយចិត្តអានសៀវភៅ មានសៀវភៅផាត់ពណ៌ មាននំខ្លះៗ មានស្វាយខ្លះៗ។ ប៉ុន្តែ មានការលើកទឹកចិត្តសម្រាប់កុមារ ដើម្បីឱ្យគេមានកម្លាំងកាយកម្លាំងចិត្តក្នុងការធ្វើដំណើរទៅមុខតទៅទៀត។

ព្រះសហគមន៍របស់យើង គឺជាគ្រួសារតែមួយនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធពិតមែន ឱ្យព្រះសហគមន៍របស់យើងចេញសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់នេះ ដើម្បីឱ្យយើងរួមគ្នាកសាងសង្គមថ្មីតាមរយៈសេចក្តីស្រឡាញ់ដែលយើងមានពីមួយថ្ងៃទៅមួយថ្ងៃ។ ពិតមែន បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះយើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះវិញ្ញាណដ៏វិសុទ្ធជម្រុញយើងឱ្យយើងទៅប្រកាសដំណឹងល្អ នៅក្នុងស្ថានភាពសព្វថ្ងៃ បីកុំបីការពារនិងបីថែរក្សា ប៉ុន្តែយើងអាចធ្វើបាន ដូច្នេះយើងត្រូវតែឈរឡើងដើម្បីឱ្យយើងរួមគ្នាប្រកាសដំណឹងល្អតទៅទៀត។

បងប្អូនជាទីស្រឡាញ់ ជារៀងរាល់ឆ្នាំនៅថ្ងៃបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ខ្ញុំថ្វាយអភិបូជាអន្តរជាតិរួមជាមួយគ្រប់សហគមន៍។ នៅក្នុងនេះ យើងមានសហគមន៍និយាយភាសាអង់គ្លេស យើងមានសហគមន៍និយាយភាសាបារាំង យើងមានសហគមន៍និយាយភាសាកូរ៉េ។ រួមជាមួយគ្នា យើងមានអភិបូជានៅផ្សារតូចជារៀងរាល់ឆ្នាំ ហើយឆ្នាំនេះដែលយើងមិនអាចធ្វើបាន ប៉ុន្តែខ្ញុំក៏សូមអនុញ្ញាតផ្តាំសួរសុខទុក្ខដល់បងប្អូននៃសហគមន៍ជនជាតិបរទេសទាំងអស់ផង។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ

អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

ប្រទេសកម្ពុជា